# ជីវប្រវត្តិដោយសង្ខេបរបស់អ្នកនិពន្ធ

ព្រះមហាថេរ **ស្រាវស្ទី ធម្មិក** ដែលជាអ្នកបាថកថាដ៏ល្បីល្បាញ បានកើតនៅក្នុងទីក្រុងមេលបើន ប្រទេសអូស្ត្រាលី ក្នុងឆ្នាំ១៩៥១។ បន្ទាប់ពីបានអានសៀវភៅធម៌ ព្រះមហាថេរ បានចាប់អារម្មណ៍ជាប់ជានិច្ចនៅក្នុងព្រះពុទ្ធសាសនាចាប់តាំងពីវ័យកុមារភាពមកម្លេះ។ ក្នុងឆ្នាំ១៩៧៦ ព្រះមហាថេរ បានធ្វើដំណើរទៅកាន់ប្រទេសឥណ្ឌា ហើយទស្សនាពុទ្ធសង្វេគជនីយ–ដ្ឋាននៅទីនោះ។ នៅឯស្រាវស្ទី ព្រះមហាថេរ បានបួសជាសាមណេរ។ ក្រោយមកព្រះមហាថេរ បានផ្លាស់ទីលំនៅទៅកាន់ប្រទេសស្រីលង្កាដើម្បីការសិក្សានិងការបដិបត្តិ។ ព្រះមហាថេរ ក៏បានបង្រៀនសមាធិអស់រយៈពេលជាច្រើនឆ្នាំផងដែរ។ ក្នុងឆ្នាំ១៩៨៥ ព្រះមហាថេរ បានធ្វើដំណើរទៅកាន់ប្រទេសសាំងកាពួរជាកន្លែងដែលព្រះមហាថេរ ទទួលឧបសម្បទានៅទីនោះ។ ក្រោយមកព្រះមហាថេរ បង្រៀននៅស្ថាប័នអភិវឌ្ឍន៍កម្មវិធីសិក្សារបស់ក្រសួងអប់រំ ដែលជាកន្លែងព្រះមហាថេរ បង្កើតខ្សែភាពយន្តទូរទស្សន៍ជាច្រើនសំរាប់ស្ថាប័ននេះ។ ព្រះមហាថេរ ធម្មិក ក៏បានបាថកថានៅតាមសកលវិទ្យាល័យផ្សេងៗ សាលារៀន ស្ថានីយ៍ទូរទស្សន៍ និងវិទ្យុនៅប្រទេសអូស្ត្រាលី និងជុំវិញទ្វីបអាស៊ី។